MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# កម្ពុជា៖ អ្នកជំនាញការ អ.ស.ប នឹងបំពេញបេសកកម្មស្វែងរកការពិត អំពីសិទ្ធិស្ត្រី និងជនជាតិដើមភាគតិច

ទីក្រុងហ្សឺណែវ/រាជធានីភ្នំពេញ (១៧ មីនា ២០១៦) – អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា សាស្ត្រាចារ្យ **រ៉ូណា ស្មីត** នឹងបំពេញទស្សនកិច្ចផ្លូវការមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២១ ដល់ខែថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ដើម្បីវាយតម្លៃអំពីការទទួលបាននូវសិទ្ធិរបស់ស្ត្រី និងជនជាតិដើមភាគតិចនៅកម្ពុជា។

"ខ្ញុំនឹងផ្ដោតលើការរើសអើង នៅក្នុងអំឡុងដំណើរទស្សនកិច្ចផ្លូវការលើកទីពីររបស់ខ្ញុំ មកកាន់ប្រទេសកម្ពុជា ដោយពិនិត្យមើលស្ថានភាពរបស់ក្រុមដែលបាត់បង់ឱកាស និងដែលគេមិនសូវគិតគូរ មានដូចជាស្ត្រី ជនជាតិដើមភាគតិច និងជនរងគ្រោះដោយការរើសអើងពូជសាសន៍ និងជាតិពន្ធ" អ្នកជំនាញការបានកត់សម្គាល់ដូច្នេះ។

"ការពិនិត្យឲ្យកាន់តែជិតដល់ថែមទៀត អំពីស្ថានភាពសិទ្ធិមនុស្ស ចំពោះក្រុមដែលបាត់បង់ឱកាស និងក្រុមដែលគេមិនសូវគិតគូរនៅប្រទេសកម្ពុជា នឹងអាចឲ្យខ្ញុំ ជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងធ្វើឲ្យសង្គមមួយមានសមធម៌ និងមានវិបុលភាព" លោកស្រី ស្មីត មានប្រសាសន៍ដូច្នេះ ទន្ទឹមនឹងនោះលោកស្រីសង្កត់ធ្ងន់ថាដំណើរទស្សនកិច្ចនេះ នឹងអនុញ្ញាតផងដែរឲ្យលោកស្រី ធ្វើការវាយតម្លៃអំពីវឌ្ឍនភាពលើបញ្ហាសិទ្ធិមនុស្សដទៃទៀតនៅកម្ពុជា។ "បេសកកម្មនេះ នឹងគ្របដណ្ដប់ផងដែរ នូវបញ្ហាកង្វល់អំពីសិទ្ធិមនុស្សមួយចំនួនចំពោះរដ្ឋាភិបាល និងប្រជាជនកម្ពុជា។"

នៅក្នុងអំឡុងនៃដំណើរទស្សនកិច្ចរយៈពេល ១០ ថ្ងៃនេះ អ្នកជំនាញឯករាជ្យរូបនេះ នឹងជួបប្រជុំជាមួយសមាជិកជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ព្រមទាំងសមាជិកព្រឹទ្ធសភា និងរដ្ឋសភា។ លោកស្រីនឹងជួបផងដែរជាមួយតំណាងសង្គមស៊ីវិល ក្រុម អ.ស.ប ប្រចាំប្រទេសកម្ពុជា និងសហគមន៍ការទូត។ អ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ រំពឹងផងដែរថានឹងធ្វើទស្សនកិច្ចនៅតាមខេត្ត ដើម្បីប្រមូលព័ត៌មានជាក់ស្ដែងដោយផ្ទាល់។

អ្នករាយការណ៍ពិសេស អ.ស.ប បំពេញទស្សនកិច្ចទៀងទាត់មកកាន់ប្រទេសកម្ពុជា និងរាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ចាប់ពីលោកស្រីទទួលបានការតែងតាំងក្នុងខែមីនា ឆ្នាំ២០១៥ មក លោកស្រីបានធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា នៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ហើយបន្ទាប់មកមិនយូរប៉ុន្មាន លោកស្រីបានរាយការណ៍ទៅសម័យប្រជុំលើទី៣០ របស់ក្រុមប្រឹក្សាសិទ្ធិ

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

មនុស្ស ដែលបានបន្តអាណត្តិរបស់លោកស្រីរយៈពេលពីរឆ្នាំបន្ថែមទៀត។ លោកស្រី ស្មីត នឹងដាក់បង្ហាញរបាយការណ៍បន្ទាប់របស់លោកស្រីទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងខែកញ្ញា ឆ្នាំ២០១៦។

អ្នករាយការណ៍ពិសេសនឹងធ្វើ**សន្និសីទកាសែត**មួយ នៅពេលបិទបញ្ចប់ដំណើរទស្សនកិច្ចរបស់លោកស្រី នៅថ្ងៃព្រហស្បតិ៍ទី៣១ ខែមីនា នៅវេលាម៉ោង ៣ រសៀល នៅការិយាល័យសិទ្ធិមនុស្សអ.ស.ប (ការិយាល័យ OHCHR) ដែលស្ថិតនៅផ្ទះលេខ១០ ផ្លូវលេខ៣០២ សង្កាត់បឹងកេងកង ១ រាជធានីភ្នំពេញ។ មានការកំណត់ចំនួនអ្នកសារព័ត៌មានដែលនឹងត្រូវផ្តិតយកព័ត៌មាននៅសន្និសីទកាសែតនេះ។

**ចប់**

*លោកស្រី **រ៉ូណា ស្មីត** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងក្នុងខែមីនា ឆ្នាំ២០១៥។ លោកស្រី រ៉ូណា ស្មីត គឺជាសាស្ត្រាចារ្យសិទ្ធិមនុស្សអន្តរជាតិ នៅចក្រភពអង់គ្លេស។ លោកស្រីបានបង្រៀនផងដែរ នូវច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងនាមជាសាស្ត្រាចារ្យទស្សនកិច្ចមួយរូប នៅប្រទេសចិន និងកាណាដា ហើយបានចំណាយពេលជាភ្ញៀវកិត្តិយសមួយរូបនៅវ៉ាណាវទូ (Vanuatu)។ សាស្ត្រា ស្មីត ក៏ធ្លាប់ជាសាស្ត្រាចារ្យទស្សនកិច្ចមួយរូបផងដែរ នៅសាកលវិទ្យាល័យ បញ្ញាសាស្ត្រនៅកម្ពុជា ដែលលោកស្រីបានធ្វើការរៀបចំតាក់តែង និងបង្កើតកម្មវិធីសិក្សា ដើម្បីប្រកាសបើកជាផ្លូវការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើកទី១ ផ្នែកច្បាប់សិទ្ធិមនុស្ស។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់៖* http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx

*អ្នករាយការណ៍ពិសេស គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យ ឃ្លាំមើល និងស្វែងរកការពិត របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អ្នកកាន់អណត្តិរបស់នីតិវិធីពិសេស ជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ដែលតែតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីដោះស្រាយទាំងស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ទាំងបញ្ហាតាមវិស័យមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគេមិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគេបម្រើការក្នុងសមត្ថភាពបុគ្គលរបស់ពួកគេផ្ទាល់ និងមិនទទួលប្រាក់បៀវត្សរ៍ពីការងាររបស់ខ្លួនឡើយ។*

*សូមផែកមើលរបាយការណ៍ស្តីពីកម្ពុជា៖* http://ap.ohchr.org/documents/dpage_e.aspx?m=107

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងនៅ**រាជធានីភ្នំពេញ៖** កញ្ញា គ្រីសស្ទីន ភិឃើរីង (Ms. Christine Pickering) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ២៣ ៩៩៣ ៥៩០/៩១ លេខភ្ជាប់បន្ត៖ Ext:  ៣០៦ ឬ អ៊ីម៉ែល* cpickering@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន** អំពីអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖

លោក សាបៀរ សេឡាយ៉ា (Xabier Celaya) អង្គភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សម្រាប់វិបសាយព័ត៌មានរបស់លោក/អ្នក និងបណ្តាញសង្គម៖** មាតិកាពហុប្រព័ន្ធផ្សព្វផ្សាយ និងសារគន្លឹះៗទាក់ទងនឹងសេចក្តីប្រកាសព័ត៌មានរបស់យើង អាចរកបាននៅលើឆាណែលបណ្តាញសង្គមសិទ្ធិមនុស្ស អ.ស.ប ដែលមានរាយឈ្មោះខាងក្រោមនេះ។ សូមថេក (tag) មកយើង ដោយប្រើផ្នែកដែលត្រូវបើកឲ្យបានត្រឹមត្រូវ៖

ទ្វីតធឺ៖ @UNHumanRights
ហ្វេសប៊ុក៖ unitednationshumanrights
Instagram: unitednationshumanrights
ហ្គោហ្គីល៖ Google+: unitednationshumanrights
យូធូប៖ unohchr